ABLE BODIED ADULT WITHOUT DEPENDENTS (ABAWD)

តម្រូវការភាពមានសិទ្ធិទទួលបានម្ហូបអាហារមូលដ្ឋាន៖ អ្វីដែលអ្នកត្រូវការដើងដើម្បីរក្សាអត្ថប្រយោជន៍របស់អ្នក

Basic Food Eligibility Requirements: What You Need to Know to Keep Your Benefits

អត្ថប្រយោជន៍របស់អ្នកគឺមានពេលវេលាកំណត់ ប្រសិនបើអ្នកមិនកំពុងធ្វើការ

យើងពិចារណាថាអ្នកជា មនុស្សពេញវ័យដែលមានរាងកាយមាំមួនដោយគ្មានអ្នកនៅក្នុងបន្ទុក (ABAWD) សម្រាប់ម្ហូបអាហារមូលដ្ឋាន ដោយសារតែអ្នកអាចធ្វើការ ហើយមិនមានកូននៅក្នុងគ្រួសាររបស់អ្នកទេ។

អ្នកអាចទទួលបានអត្ថប្រយោជន៍ម្ហូបអាហារមូលដ្ឋានសម្រាប់ពេលបីខែចេញពីរយៈពេលរ្យៀងរាល់ 36 ខែ ប្រសិនបើអ្នកមិនកំពុងបំពេញបានតាមតម្រូវការការងារ។

របៀបរក្សាអត្ថប្រយោជន៍ម្ហូបអាហារមូលដ្ឋានរបស់អ្នក

អ្នកត្រូវតែធ្វើសកម្មភាពមួយ ឬច្រើនដូចខាងក្រោម ដើម្បីរក្សាទុកអត្ថប្រយោជន៍របស់អ្នកសម្រាប់ពេលលើសពីបីខែ៖

- បំពេញការងារស្ម័គ្រចិត្តតាមរយៈកម្មវិធីថ្លៃឈ្នួលការងាររាល់ខែ។ ចំនួនអត្ថប្រយោជន៍ប្រចាំខែរបស់អ្នកកំណត់ពីចំនួនម៉ោងដែលអ្នកត្រូវតែស្ម័គ្រចិត្តដើម្បីរក្សាអត្ថប្រយោជន៍ម្ហូបអាហាររបស់អ្នក។
- ធ្វើការយ៉ាងហោចណាស់ 20 ម៉ោងក្នុងមួយសប្តាហ៍ ឬ 80 ម៉ោងក្នុងមួយខែ ជាមធ្យម។
- ចូលរួមក្នុងការងារ ឬកម្មវិធីបណ្តុះបណ្តាលដែលបានអនុម័តដោយរដ្ឋ ដូចជា៖
  - ការងារ និងការបណ្តុះបណ្តាលអំពីម្ហូបអាហារមូលដ្ឋាន (BFET)។ សម្រាប់ព័ត៌មានបន្ថែម ចូលទៅកាន់ www.dshs.wa.gov/bfet;
  - កម្មវិធីទានាដែលរួមមាននៅក្នុង ច្បាប់ទទួលបានការងារ និងឱកាសកម្លាំងការងារ (WIOA)។ សម្រាប់ព័ត៌មានបន្ថែម ចូលទៅកាន់ https://www.dshs.wa.gov/esa/community-services-offices/wioa; ឬ
  - AmeriCorps VISTA ។

ឧបសគ្គទានាចំពោះការចូលរួម

ទាក់ទងមកយើង ប្រសិនបើអ្នកមិនអាចចូលរួមយ៉ាងហោចណាស់ ៨០ ម៉ោងក្នុងមួយខែបាន ដោយសារតែអ្នក៖

- មានពិការភាពខាងរាងកាយ ឬផ្លូវចិត្ត
- ទទួលបានអត្ថប្រយោជន៍ពី ធានារ៉ាប់រងពលកម្ម និងឧស្សាហកម្ម (Labor & Industries, L&I), រដ្ឋបាលអតីតយុទ្ធជន ឬធានារ៉ាប់រងពិការភាពឯកជន
- រស់នៅក្នុងលក្ខខណ្ឌដែលជាឧបសគ្គចំពោះការងារ
- ការថែទាំសម្រាប់បុគ្គលដែលមិនអាចថែទាំសម្រាប់ខ្លួនពួកគេផ្ទាល់ ដោយសារតែអាយុ ឬពិការភាព
- ចូលរួមក្នុងការព្យាបាលលើការពឹងផ្អែកខាងសារធាគីមី ឬកម្មវិធីស្តារនីតិសម្បទា
- បានដាក់ពាក្យសុំ ឬទទួលបានអត្ថប្រយោជន៍ពីភាពគ្មានការងារធ្វើ
- ត្រូវបានចុះឈ្មោះចូលរៀនយ៉ាងហោចណាស់ពាក់កណ្តាលពេល ឬ
- ទទួលបានអត្ថប្រយោជន៍ជំនួយសាច់ប្រាក់សម្រាប់ជនភៀសខ្លួន ឬមូលនិធិផ្តល់ការផ្លូវផ្លង ឬ
- ចូលរួមក្នុងកម្មវិធី LEP Pathway ឬ CLEVER ។

រឿងរ៉ាវទានាដែលអ្នកត្រូវរាយការណ៍

អ្នកត្រូវតែប្រាក់យើង ប្រសិនបើ៖

- អ្នកមិនអាចបំពេញចំនួនម៉ោងចូលរួមដែលបានតម្រូវក្នុងពេលមួយខែ។
- ការងាររបស់អ្នកធ្លាក់ចុះក្រោម 20 ម៉ោងក្នុងមួយសប្តាហ៍។
- ប្រាក់ចំណូលគ្រួសាររបស់អ្នកទៅលើសពីដែនកំណត់នៅក្នុង WAC 388-478-0060។
- អ្នក ឬសមាជិកគ្រួសាររបស់អ្នកទទួលបានប្រាក់ឈ្នះឆ្នោត ឬការភ្នាល់ល្បែងជាសក្តានុពលនៅក្នុងហ្គេមទោលមួយដែលស្មើនឹង ឬលើសពីដែនកំណត់នៅក្នុង WAC 388-470-0006(8)(a)។

អ្នកអាចស្វែងរកព័ត៌មានបន្ថែមអំពីតម្រូវការ ABAWD បាននៅ www.dshs.wa.gov/abawd។

ហៅទូរសព្ទមកយើងតាមរយៈលេខ 1-877-501-2233 ប្រសិនបើអ្នកមានសំណួរផ្សេងៗ។ ត្រូវការជំនួយក្នុងការភ្ជាប់ទៅកាន់កម្មវិធីបណ្តុះបណ្តាល ឬត្រូវការរាយការណ៍ពីការផ្លាស់ប្តូរទានា។

អ្នកអាចចូលមើលយើងនៅ www.washingtonconnection.org ដើម្បីដាក់ពាក្យសុំអត្ថប្រយោជន៍ទានា ដាក់ស្នើការពិនិត្យឡើងវិញ ឬ រាយការណ៍ពីការផ្លាស់ប្តូរទានា។